# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**

**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

## សេចក្ដីថ្លែងការណ៍

សហគមន៍ខ្មែរកម្ពុជាក្រោម សម្ដែងនូវសេចក្ដីសោកស្ដាយយ៉ាងខ្លាំងចំពោះសាលាដំបូងខេត្តតាកែវដែលបានកាត់ទោសលោក**ថាច់ ឡេ** លោក**ថាច់ វណ្ណៈ** និងលោក**លាង សុខជឿន** បុគ្គលិករដ្ឋបាលអង្គការលីកាដូឲ្យជាប់ព័ន្ធនាគារម្នាក់ៗចំនួន២ឆ្នាំ និងពិន័យជាប្រាក់ ២ ០០០ ០០០ (ពីរលាន) រៀល ព្រមទាំងកាត់ទោសព្រះតេជគុណ**ថាច់ ក្លុងភ្លួង** ដោយកំបាំងមុខឲ្យជាប់ពន្ធនាគារចំនួន៣ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល កាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០ ពីបទផ្សាយព័ត៌មានមិនពិត ព្រោះបានបាចខិតប័ណ្ណប្រឆាំងថ្ងៃ៧មករា ។

យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា ៤១ បានចែងជាអាទិ៍ថា ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន *សេរីភាពខាងការបោះពុម្ពផ្សាយ........* ។ ការចោទប្រកាន់របស់តុលាការខេត្តតាកែវ មកលើលោក**ថាច់ ឡេ** លោក**ថាច់ វណ្ណៈ** លោក**លាង សុខជឿន** និងព្រះតេជគុណ**ថាច់ ក្លុងភ្លួង** ជាអំពើអយុត្តិធម៌បំផុតមិនអាចទទួលយកបានឡើយ ។ ពីព្រោះអ្នកដែលប្រឆាំងថ្ងៃ៧មករា ហើយបានកំណត់ថា ជាថ្ងៃយួនឈ្លានពានប្រទេសកម្ពុជា មានទាំងសហគមន៍ជាតិ និងអន្តរជាតិ រហូតដល់មានការគាបសង្កត់ពីសហគមន៍អន្តរជាតិបង្ខំឲ្យយួនដកកងទ័ពទាំងស្រុងចេញពីប្រទេសកម្ពុជា និងមានចលនាតស៊ូប្រដាប់អាវុធតាមជាយដែនខ្មែរ-ថៃ ប្រឆាំងថ្ងៃ៧មករា រហូតដល់មានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារី ២៣ តុលា ១៩៩១ ។ បច្ចុប្បន្ន គណបក្សប្រឆាំង សារព័ត៌មានប្រឆាំង បានវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើថ្ងៃ៧មករា ហេតុដូចម្ដេចក៏គ្មានទោសពៃរ៍ ?

ផ្ទុយទៅវិញ លោក**ថាច់ ឡេ** លោក**ថាច់ វណ្ណៈ** លោក**លាង សុខជឿន** និងព្រះតេជគុណ**ថាច់ ក្លុងភ្លួង** មានប្រយោជន៍អ្វី ក្នុងការប្រឆាំងថ្ងៃ៧មករា ព្រោះអស់លោកទាំងនោះ មិនមែនជាគណបក្សនយោបាយប្រឆាំង មិនមែនជាចលនាតស៊ូដើម្បីផ្ដួលរំលំរដ្ឋាភិបាលផងនោះ ?

តាមការស្រាវជ្រាវរបស់សហគមន៍ខ្មែរកម្ពុជាក្រោម បានបង្ហាញឲ្យឃើញថា អ្នកទាំងអស់នោះពុំមានជាប់ពាក់ព័ន្ធក្នុងករណីដូចការចោទប្រកាន់របស់តុលាការខេត្តតាកែវនោះឡើយ ។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមអំពាវនាវយ៉ាងទទូចដល់សាលាឧទ្ធរណ៍ និងតុលាការកំពូល មេត្តាពិចារណាឡើងវិញចំពោះសាលក្រមសាលាដំបូងខេត្តតាកែវ និងមេត្តាលើកលែងការចោទប្រកាន់ទាំងស្រុងមកលើលោក**ថាច់ ឡេ** លោក**ថាច់ វណ្ណៈ** លោក**លាង សុខជឿន** និងព្រះតេជគុណ**ថាច់ ក្លុងភ្លួង** ។

រាជធានីភ្នំពេញ, … ឆ្នាំ២០១០

**អគ្គលេខាធិការដ្ឋានសហគមន៍ខ្មែរកម្ពុជាក្រោម**

THE KHMER KAMPUCHEA KROM COMMUNITY

**ទីស្នាក់ការបណ្ដោះអាសន្នផ្ទះលេខ:** 10B **ផ្លូវលេខ** 234 **សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ**

**ទូរស័ព្ទលេខ: (៨៥៥) ១២ ៩០៨ ៨៨២ / ០៩០ ៥៣៣ ០០៣**

E-mail: senthach2000@yahoo.com; Website: http//khmerkromngo.org